# សមាជចុងក្រោយនៃសង្គមរាស្ត្រនិយម

ដោយ សុទ្ធ-ប៉ូលិន

អត្ថបទដកស្រង់ចេញពីសៀវភៅ

**Cambodge - Le Chemin de l'Apocalypse**

នៅព្រឹកថ្ងៃទី២៥ធ្នូ (១៩៦៩) ដោយមានការជ្រួលច្របល់ក្នុងសតិអារម្មណ៍ខ្លាំងពេក ខ្ញុំក៏បានទៅផ្ទះរបស់លោកលន់-ណុន ។ ខ្ញុំបានឃើញគាត់ហៅសូត្រដោយសម្លេងខ្លាំងៗ ឲ្យថោង-លឹមហួងសរសេរអត្ថបទមួយ ។ គឺជាអត្ថបទមួយដ៏សំខាន់ណាស់ ដែលគេបំរុងយកទៅចុះនៅក្នុង «ប្រយោជន៍ខ្មែរ» ដែលជាកាសែតមួយដែលពុំមាននរណាស្គាល់ ហើយដែលមានបោះពុម្ពផ្សាយចំនួនតែពីរពាន់ច្បាប់ ។ ប្រសិនបើគេតម្រូវឲ្យយកអត្ថបទនោះ មកចុះផ្សាយក្នុងសារពត៌មានរបស់ខ្ញុំវិញ (នគរធំ) ខ្ញុំច្បាស់ជាមិនហ៊ានទទួលយកទេ ។ ខ្ញុំមានអាកប្បកិរិយាដូចសត្វឆ្មារលាកទឹកក្តៅ ដែលភ័យខ្លាចទឹកត្រជាក់ (ដោយខ្ញុំទើបបានត្រូវជាប់ចោទរបស់ព្រះរាជអាជ្ញា សៅ-វ៉ា ដៃស្តាំរបស់យមរាជយ៉ែម-សំបូរ ថ្មីៗនៅឡើយ ថាបានធ្វើវិទ្ធង្សនា «ប្រឆាំងនឹងសង្គមរាស្ត្រនិយមរបស់សម្តេចឪ» កាលខ្ញុំមានឋានៈជាចាងហ្វាងនៃកាសែត «ខ្មែរឯករាជ្យ» របស់លោកស៊ឹម-វ៉ារ) ។ បើនិយាយតាមភាសាខ្មែរវិញ... ខ្ញុំឃើញអាចម៍ខ្លាក៏ភ័យដែរពេលនោះ កុំសូម្បីឡើយឃើញសត្វខ្លា ។

អត្ថបទដែលលោកលន់-ណុនកំពុងហៅសូត្រដល់លោកថោង-លឹមហួង គឺមានគោលបំណងរត់ជល់យ៉ាងពេញទំហឹង ទៅលើនយោបាយសេដ្ឋកិច្ចដ៏អភ័ព្វរបស់ព្រះប្រមុខរដ្ឋ ។ លោកលន់-ណុនបានរៀបចំផ្សាយអត្ថបទនេះ ដើម្បីជួយគាំទ្រអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈក្នុងឱកាសសមាជជាតិ នៅពេលប៉ុន្មានថ្ងៃខាងមុខទៀតនេះ ។ ឬក៏គំនិតនេះ វាបានផុសចេញឡើងពីទ្រង់សិរិមតៈដោយផ្ទាល់តែម្តងក៏ពុំដឹង ដោយហេតុថាលោកលន់-ណុនពុំមែនជាមនុស្សស្វាហាប់ក្លាហានក្នុងប្រការបញ្ចេញស្នាដៃជាបញ្ញាជននោះទេ ។ ម្យ៉ាងវិញទៀត លោកស័ក្តិប្អូនលន់-ណុនបានទទួលបញ្ជាដាច់ណាត់ ពីលោកឧត្តមសេនិយបងរបស់លោក ឲ្យបំរើទ្រង់សិរិមតៈដូចជាបងរបស់ខ្លួនឯងបង្កើត ក្នុងប្រការអ្វីៗដែលមានចំណាត់ការទាក់ទងនឹងរដ្ឋាភិបាល ។ ជាការច្បាស់ណាស់ លោកលន់-ណុនបានប្រាប់ពួកយើងថា លោកទើបតែបានជួបទ្រង់កាលពីថ្ងៃម្សិល ដោយពុំបានធ្វើអត្ថាធិប្បាយវែងឆ្ងាយ ។

ការហៅសូត្រ (dictée) បានប្រព្រឹត្តទៅអស់រយៈពេលជាងមួយម៉ោង ។ គឺជាអត្ថបទមួយវែងអន្លាយ តែមានជំរៅក្នុងការវិភាគ ហើយភ្លឺថ្លាដូចកញ្ចក់ក្នុងការចោទប្រកាន់ ។ មួយចំណុចម្តងៗ អត្ថបទនេះបានធ្វើសំណើឲ្យមានការវិលត្រឡប់នូវសេដ្ឋកិច្ចសេរី ដែលជាឱសថសំរាប់កែរោគរាំងស្ទះនៅប្រទេសកម្ពុជា ដែលបណ្តាលមកពីការដឹកនាំងងឹតងងល់ដ៏តឹងរ៉ឹងមួយ (តាមផ្លូវសេដ្ឋកិច្ច) ពោរពេញដោយអនាធិបតេយ្យជាយូរឆ្នាំណាស់មកហើយ ហើយនៅទីបំផុតក៏មានសំណើឲ្យបិទទ្វារក្រុមហ៊ុនរដ្ឋទាំងប៉ុន្មាន ព្រមទាំងឲ្យបញ្ឈប់នយោបាយជាតូបនិយកម្មបែបសង្គមនិយម ។ នៅពេលនោះ ខ្ញុំព្រឺស្រៀវដល់ឆ្អឹងខ្នងមួយរំពេជ បើទោះជាខ្ញុំមានអាកប្បកិរិយានឹងថ្កល់ គ្មានកំរើកសូម្បីតែបន្តិចក៏ដោយ ។ អត្ថបទបែបដូចនេះ ច្បាស់ជាបណ្តាលឲ្យមានការភ្ញាក់ផ្អើលភ្លូកទឹកភ្លូកដីជាមិនខាន, ខ្ញុំនឹកក្នុងចិត្ត ។ គ្រាប់បែកបែបនេះ នឹងផ្ទុះឡើងចំព្រះភក្ត្រសម្តេច នៅចំកណ្តាលសមាជជាតិតែម្តង ។ ពីព្រោះព្រះបិតានៃសេដ្ឋកិច្ចសង្គមនិយម គឺគ្មាននរណាក្រៅពីសម្តេចសីហនុនេះឯង ។ ហ៊ានបុកទង្គិចជាមួយក្រុមហ៊ុនរដ្ឋ គឺជាការសាកល្បង«បំបែកឆ្នាំងបាយ»របស់ស្តេចសីហនុនិងអ្នកម្នាងម៉ូនិក ព្រមទាំងក្លូវរបស់ទ្រង់ដ៏មហិមាដែលមានក្បាលពស់នាគរាជពីរដ៏សំបើម ចាំព្រួសភ្លើងមរណៈនៃភេរវកម្ម គឺក្បាលអារក្សសាតាំង អ៊ុម-ម៉ាណូរិន, មេកងប៉ូលីសសម្ងាត់របស់ស្តេច និងក្បាលនាគខែក-វណ្ណី មេក្រុមចោរម៉ាហ្វីយ៉ានៅចំការមន ។

⌘

⌘ ⌘

ថ្ងៃសៅរ៍ទី២៧ធ្នូ, ថ្ងៃទី១នៃសមាជជាតិចុងក្រោយដ៏គួរឲ្យតក់ស្លុតរន្ធត់ (ពីព្រោះ មានពាក្យថា សម្តេចត្រូវរំលាយរដ្ឋាភិបាលនៅពេលនោះ) ក៏បានមកដល់។ នៅពេលបើកសមាជ, សម្តេចសីហនុដែលជាប្រធាននៃ«សង្គមរាស្ត្រនិយម»ដោយទំនៀមទំលាប់ គឺមិនមែនដោយសារការបោះឆ្នោត ក៏មានសំនួនវោហារព្រោកប្រាជ្ញបែកអូរហូរជាស្ទឹងដូចសព្វមួយដង, ដោយទ្រង់ប្រឹងច្រៀងអាយ៉ៃអួតអាងពីស្នាដៃរបស់ទ្រង់ និងពីសមិទ្ធិ«ដ៏ស្លេកស្លាំងបែកមែកសាខា» ។ ប៉ុន្តែនៅពេលនោះ ខ្ញុំមានអារម្មណ៍ថា ព្រះប្រធាននៃ«សង្គមរាស្ត្រនិយម»ពុំមាននរណាស្រឡាញ់ទៀតទេ ។ គ្រាន់តែព្រះបិតាជាតិបានបញ្ចេញឃ្លោងឃ្លាដំបូងរបស់ទ្រង់ ខ្ញុំក៏បានដឹងរួចទៅហើយថា ម្តងនេះសម្តេចខំប្រឹងការពារខ្លួនឯង ។ ចរន្តនៃសេចក្តីស្មោះត្រង់ហាក់ដូចជាមិនបានទម្លុះជញ្ជាំងគរថ្លង់ដ៏ក្រាស់នៃមហាជនខ្មែរនៅពេលនោះសោះ ដែលសព្វដងធ្លាប់តែទះដៃហ៊ោរកញ្ជៀវអ៊ឹងកង ទទួលស្វាគមន៍សង្កថាព្រះប្រមុខរដ្ឋ ។ អ្នកផងនៅមានសេចក្តីខ្លាចរអារចំពោះព្រះអង្គពិតមែន ប៉ុន្តែគ្មាននរណាយកចិត្តទុកដាក់ស្តាប់ឬក៏មានជំនឿលើសំដីរបស់ទ្រង់ទៀតទេ ទោះពួកជនបរទេសក្តី ទោះប្រជារាស្ត្ររបស់ព្រះអង្គក្តី ។ ទាំងនេះហើយជាសញ្ញាចាប់ផ្តើមនៃបរាជ័យធ្លាក់រមៀលមូរនបនៃព្រះអគ្គមគ្គុទ្ទេសក៍ ។ សម្តេចព្រះប្រធានកំពុងតែខំប្រឹងទេសនានៅវាលរហោស្ថានសោះខ្យល់ ។ ព្រះប្រធានពុំមានលក្ខណៈជាស្តេចទាល់តែសោះ គឺគ្រាន់តែជាសត្វខ្ទួយមួយ ដែលកំពុងត្រូវរលាកនឹងងងើកភ្លើង ។ តើព្រះអង្គមានដឹងខ្លួនឬទេ ? ។ ប៉ុន្តែដោយព្រះអង្គភូតភរខ្លួនឯងមិនចេះចប់ ព្រមទាំងទទួលតែសេចក្តីបញ្ចើចបញ្ចើរពីអ្នកនៅជុំវិញទ្រង់ ធ្វើម្តេចទ្រង់ដឹងខ្លួនទៅបាន ?? ។

ចំណែកខ្ញុំវិញ ខ្ញុំលាក់ខ្លួនពួនសម្ងំក្នុងការិយាល័យ ដូចតែកាលពីសម័យកាសែត«ខ្មែរឯករាជ្យ» ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំមិនអាចចេញទៅក្រៅបានទេ ដោយហេតុខ្ញុំត្រូវបញ្ចប់កាសែតរបស់ខ្ញុំរៀងរាល់ថ្ងៃរសៀល ។ អត្ថបទទាំងអស់ត្រូវបានរៀបចំសំរាំងរួចជាស្រេច... កាត់កែរកង បន្ថយបន្ថែម មុននឹងយកទៅបញ្ចូលរោងពុម្ពវេលាម៉ោង២, ក្នុងប្រការបានទទួលសារពត៌មានរបស់យើងរាប់រយច្បាប់ ឲ្យពួកក្មេងៗយកទៅលក់តាមទីផ្សារមុនពេលរាត្រីធ្លាក់ ។ ប៉ុន្តែខ្ញុំប្រឹងតាមវិភាគរបស់សមាជដោយស្តាប់វិទ្យុជាតិ ។ ដោយលើកជើង ដែលមានពាក់ Cowboy boot គងដាក់លើតុ ហើយផ្អែកកៅអីផ្ទប់នឹងជញ្ជាំង ដោយបិទភ្នែកពាក់កណ្តាល ដូចមនុស្សទំរេតពេលថ្ងៃត្រង់... តាមពិតខ្ញុំខំប្រឹងស្តាប់ដោយភ័យភិតតក្កមា ។

ដោយទិវាទី២នៃអង្គសមាជត្រូវជាថ្ងៃអាទិត្យទី២៨ធ្នូ១៩៦៩, ខ្ញុំក៏បានរៀបចំ «ទស្សនៈរើរវាយ»មួយសំរាប់បោះផ្សាយនៅថ្ងៃអាទិត្យ ។ ដោយមានពុកពារអាកប្បកិរិយាដូចមនុស្សឆ្កួត, ខ្ញុំបានសាកល្បងបញ្ជូនសារសម្ងាត់មួយទៅមិត្តអ្នកអានថាមនុស្សឆ្កួតពិតប្រាកដនោះ គឺសម្តេចព្រះប្រមុខរដ្ឋ ដែលគេមិនត្រូវដើរតាមទាំងខ្វាក់ងងឹតងងល់នោះទេ ។ ខ្ញុំបានសាកល្បងពន្យល់ដល់ជនជាតិខ្មែរ កុំឲ្យហូប«ស្មៅពុល»ដូចហ្វូងចៀម តាមការណែនាំរបស់ប្រមុខរដ្ឋ ហើយកុំឲ្យតាមចោះដូចហ្វូងសត្វឆ្មាត ទៅលើពួកណាដែលទ្រង់ចាត់ទុកជាខ្មាំងសត្រូវ ។ ខ្ញុំក៏បានឆ្លៃប្រឌិតរឿងហ្វូងចៀមរបស់ Panurge... ហើយក៏បានបង្ហាញថា យោបល់របស់ក្រុមជនភាគច្រើន មិនមែនចេះតែល្អនោះទេ ។ យោបល់ភាគច្រើន ដែលជាលទ្ធផលនយោបាយប្រជាភិថុតិ ជួនកាលមានលក្ខណៈជាទង្វើសម្លាប់ខ្លួន នៅពេលណាដែលមេដឹកនាំបានធ្លាក់ចូលទៅក្នុងវិកលចរិត ។ ពួកអាល្លឺម៉ង់ណាស៊ី ដែលបានដើរ

តាម Hitler ដោយសេចក្តីស្រឡាញ់ងប់ងល់ គឺសុទ្ធសឹងតែជាក្រុមជនភាគច្រើន ។ លទ្ធិប្រជាធិបតេយ្យរបស់ពួកគេកាលនោះបានក្លាយទៅជា ជម្ងឺអត្តឃាត ។ ប្រទេសជាតិរបស់គេបានធ្លាក់ទៅក្នុងភាពហិនហោចមហាអន្តរាយនៃភ្លើងឆេះក័ល្បនៃ«អស្តង្គតរបស់ព្រះជាម្ចាស់» នៅពេលដែលមគ្គុទ្ទេសក៏របស់ពួកគេ, Hitler ឬយេហ្វូវ៉ា ពាក់ស្បែកជើង Boot បានធ្វើការសម្លាប់ខ្លួន ។ ប៉ុន្តែរឿងអភ័ព្វ គឺពួកជនឆ្កួតមិនដែលដឹងថាខ្លួនឆ្កួតសោះឡើយ ។ «មនុស្សឆ្កួត, Chesterton បានពោល, គឺជាជនដែលបានបាត់បង់នូវអ្វីៗទាំងអស់ នៅសល់តែថាខ្លួនឯងត្រូវប៉ុណ្ណោះ (Le fou, c'est celui qui a tout perdu, sauf la raison) ។

⌘

⌘ ⌘

ទិវាទី១នៃសមាជជាតិមានដំណើរប្រព្រឹត្តទៅដោយគ្មានឧប្បត្តិហេតុអ្វីធំដុំទេ តាមពិតនៅវេលារសៀល វាមានការដាក់ពាក្យលាលែងបន្តបន្ទាប់គ្នានៃរដ្ឋមន្ត្រី៤នាក់របស់រដ្ឋាភិបាលស្រោចស្រង់ជាតិ... ប៉ុន្តែរឿងនេះពួកយើងបានដឹងជាមុនរួចស្រេចអស់ទៅហើយ ។ សម្តេចសីហនុព្រះប្រមុខរដ្ឋអង្គឯង ជាអ្នកប្រកាសផ្សាយអំពីការលាលែងម្តងទាំង៤ របស់លោកអ៊ឹង-ហុងសាធ (ឧបនាយករដ្ឋមន្ត្រីទី២), លោកទេព-ឈឺវខេង (ឃោសនាការ), ជួន-សៅឌី (កសិកម្ម) និងស្រី-ប៊ុង (សាធារណការ)...។ សម្តេចសីហនុនៅពេលលើកបញ្ហានេះបង្ហាញដល់វាគ្មិននៃអង្គសមាជ ហាក់ដូចជាគ្មានជំនឿលើខ្លួនឯងសោះ ពោលដូចជាគ្មានពាក្យអធិប្បាយផ្តែផ្តាប្រកបដោយពិសពុលដូចសព្វមួយដងផង ។ ទោះជាយ៉ាងណាក្តី ពួករដ្ឋមន្ត្រីលាលែងពីតំណែងទាំងនេះ សុទ្ធសឹងតែជាកូនជីងរបស់ទ្រង់ ។ ខ្ញុំមានអារម្មណ៍ដឹចម្លែកថា សម្តេចព្រះប្រមុខរដ្ឋហាក់ដូចជាពុំសូវមានសមានចិត្តគាំទ្រពួកកូនជីងដែលធ្វើ«ពលី»នេះប៉ុន្មានទេ ។ សម្តេចមានឫកពារម្អែម្អួយម៉្វែរម៉្វរត្អូញត្អែរបែកត្រប៉ែរ... ប៉ុន្តែតាមពិតទ្រង់ហាក់ដូចជាគ្មានក្តីទោមនស្សទាល់តែសោះ ក្នុងប្រការបង្ខំទម្លាក់ពួកមន្ត្រីទាំងនេះចោលដូចដុំគ្រួស... ថ្វីបើពួកទាំងនេះបានប្រថុយប្រថានជីវិតដើម្បីជួយព្រះអង្គ (ព្រលំរដ្ឋាភិបាលស្រោចស្រង់ជាតិ) ។ ខ្ញុំចោទសំនួរខ្លួនឯង (ដោយពុតត្បុតដ៏ក្រាស់ឃ្មឹកផងដែរ... ពីព្រោះពេលនោះខ្ញុំបន់ស្រន់ឲ្យសីហនុទទួលបរាជ័យ)... ថាហេតុអ្វីបានជាពួករដ្ឋមន្ត្រីភ្លីភ្លើអស់ទាំងនេះប្រញាប់បត់កលោតទឹកអ៊្វីម៉្លេះ... បើចៅហ្វាយរបស់ពួកខ្លួនមិនទាន់លោតផង ។ ម៉្យាងវិញទៀត បើសម្តេចមានចេតនាចង់រំលាយរដ្ឋាភិបាលនេះពិតមែន ម្តេចបានជាព្រះអង្គមិនបានជំរុញរដ្ឋមន្ត្រីសីហនុនិយមដ៏សំបើមពីរនាក់ គឺសុស្តែន-ហ្វែរណាង់ដែស និងអ៊ុម-ម៉ាណូរិន ឲ្យដកថយទៅ... ក្នុងប្រការឲ្យរដ្ឋាភិបាលមានការបាក់ឡុង ទន់ក្បាលជង្គង់ជាទីបំផុត ។ នេះមិនគឺជាភស្តុតាង អំពីចិត្តឃ្លេងឃ្លោងរបស់ស្តេចសីហនុទេឬ ដែលចង់រស់នៅជាមួយនឹងរដ្ឋាភិបាលដែលខ្លួនប្រកាសថាស្អប់ខ្ពើម !! ។

នៅពេលនោះ ទ្រង់សិរិមតៈពុំមានទន់ចិត្តសោះឡើយ ។ ទ្រង់យល់ព្រមទទួលយកជាឧឡារិកនូវការលាលែងរបស់រដ្ឋមន្ត្រីទាំង៤ ហើយបានបង្ហាញនូវសមានចិត្តឥតរង្គោះរង្គើបន្តកិច្ចការងាររបស់ទ្រង់ ដោយមិនចាំបាច់វត្តមានរបស់ពួកនេះ ។ គឺនៅចំពេលនោះតែម្តង ដែលសម្តេចសីហនុខំប្រឹងស្រង់ដើមរបស់ទ្រង់មកវិញ ដោយធ្វើដំណើរយ៉ាងឆ្កាំឆ្កង ចង់បញ្ចូលពួកលាលែងទាំងនេះ ទៅក្នុងរដ្ឋាភិបាលឡើងវិញ ដោយរង់ចាំការវិលត្រឡប់របស់ឧត្តមសេនិយលន់-នល់ ដែលជានាយករដ្ឋមន្ត្រីពិតប្រាកដ ។ ប៉ុន្តែវាយឺតពេលបន្តិចទៅហើយ ដោយសម្តេចសីហនុបានជួបប្រទះនឹងការមោះមុតរបស់ទ្រង់សិរិមតៈ ដែលថ្លែងប្រាប់ដល់អង្គសមាជថា ការលាលែងពីតំណែងនេះ មិនមែនជារឿងកំប្លុកកំប្លែងនោះទេ ។ ដោយយល់ថា ទ្រង់មិនអាចបង្ខិតបង្ខំពួកជនដែលពុំមានឧត្តមគតិដូចគ្នា ហើយដែលពុំមានឆន្ទៈបំពេញកិច្ចការជាមួយនឹងទ្រង់ ឲ្យនៅក្នុងរដ្ឋាភិបាលរបស់ទ្រង់ ទ្រង់សិរិមតៈហាក់ដូចជាធ្វើការផ្តើនដាក់សីហនុដោយចំហ... ៖ «ម៉េចឯងចង់រករឿងអញឬ ? អញនៅទីនេះហើយ...ឯងចង់ធ្វើអីធ្វើទៅ !» ។ ដោយសេចក្តីអាម៉ាស់ ស្តេចសីហនុគ្រាន់តែនិយាយរំអួយថា ទ្រង់គ្រាន់តែចង់ឲ្យមាន«សាមគ្គីជាតិ» តែប៉ុណ្ណោះ...រួចហើយសម្តេចក៏ធ្វើការដកថយមួយជំហាន ។

ក៏ប៉ុន្តែខ្ញុំនៅតែពុំមានសេចក្តីទុកចិត្តទាល់តែសោះ ចំពោះសភាពការណ៍ផ្អៀងផ្អង ដោយហេតុថាប្អូនរបស់លោកឧត្តមសេនិយ គឺលោកលន់-ណុនបានប្រាប់ខ្ញុំជាមុន អំពីការលាលែងពីតំណែងរបស់រដ្ឋមន្ត្រីទាំង៤ ។ ការរំលឹកឈ្មោះរបស់ឧត្តមសេនិយលន់-នល់នៅពេលនោះ (ដោយសម្តេចសីហនុ) គឺគ្រាន់តែបានបង្ហាញនូវសភាពឃ្លេងឃ្លោងរបស់រដ្ឋាភិបាលស្រោចស្រង់ជាតិ ។ ប្រសិនបើស្តេចសីហនុចង់ធ្វើការព្រលំរដ្ឋាភិបាលពិតមែន ព្រមទាំងពួកក្រុមរដ្ឋសភា ដែលសុទ្ធសឹងតែជាពួកអ្នកបំរើដាច់ថ្លៃរបស់ព្រះអង្គ, នោះទ្រង់គ្រាន់តែទាមទារឲ្យលោកលន់-នល់ត្រឡប់មកវិញ ក៏ជាការស្រេចទៅហើយ ។ ម៉្យាងវិញទៀត អវត្តមានដ៏យូរលង់របស់លោកឧត្តមសេនិយ (ពេលនោះលោកទៅព្យាបាលរោគនៅប្រទេសបារាំង... នៅក្នុង My war with the CIA ស្តេចសីហនុបានសរសេរថា « លោកលន់-នល់ទៅព្យាបាលរបួស ដែលបណ្តាលមកពីលោកឧត្តមសេនិយញ៉ឹក-ជូឡុងជាគូប្រជែង ធ្វើឲ្យក្រឡាប់ឡាន)... ការបាត់ខ្លួនរបស់លោកលន់-នល់នេះ ក៏វាជាសេចក្តីសំអាងគ្រប់គ្រាន់ ដើម្បីព្រលំរដ្ឋាភិបាលស្រោចស្រង់ជាតិរួចទៅហើយ ។ សមាជាតិនេះមិនមែនជាមធ្យោបាយចាំបាច់ ក្នុងប្រការសងសឹករបស់ស្តេចសីហនុនោះឡើយ ។ សម្តេចព្រះប្រមុខរដ្ឋនៅពេលនោះ នៅតែទទួលសេចក្តីគាំទ្រនៃពួកប្រជាជនមូលដ្ឋាននៃ«សង្គមរាស្ត្រនិយម»... ចំណែកទ្រង់សិរិមតៈវិញគ្មានមន្តស្នេហ៍ជាមួយប្រជារាស្ត្រថ្នាក់ក្រោមនោះទេ ។ នៅក្នុងឱកាសអវត្តមានរបស់លោកលន់-នល់ សេចក្តីគាំទ្ររបស់កងទ័ពចំពោះ«នាយករដ្ឋាភិបាលប្រតិភូ» (សិរិមតៈ) ច្បាស់ជាចោទឡើងជាបញ្ហា ។ ម៉្យាងវិញទៀត បើទ្រង់សិរិមតៈមានគោលជំហររឹងមាំដូចផ្ទាំងថ្មតទល់នឹងសីហនុ... លន់-នល់វិញមានតែចំណុចទន់ខ្សោយពីគ្រប់ជ្រុងជ្រោយចំពោះសម្តេច ។ នរណាៗក៏ដឹងដែរ លោកឧត្តមសេនិយមិនដែលមានឆន្ទៈរឹងទទឹងជាមួយនឹងព្រះអង្គទេ ។ មានពេលខ្លះ ខ្ញុំចោទជាសំនួរសំរាប់ខ្លួនឯង អំពីល្បែងបិទពួន អំពីការត្រូវដងត្រូវផ្លែដ៏សម្ងាត់រវាងសម្តេចសីហនុហើយនិងឧត្តមសេនិយលន់-នល់ ។ មិនស្រួលៗ ទ្រង់សិរិមតៈជាអ្នកចាញ់បោកគេនៅក្នុងរដ្ឋាភិបាលស្រោចស្រង់ជាតិ ដូចតែសត្វ«កង្កែបបោក»ដែលសំរាប់តែគេបោកស៊ី (Le dindon de la farce) ។ នៅពេលនោះ ខ្ញុំបន់ស្រន់ឲ្យស្តេចទាំងពីរ សីហនុហើយនិងសិរិមតៈ ព្រលះគ្នាណាណីតែម្តង ឲ្យឃើញសខ្មៅ ។ ប៉ុន្តែតាមពិតគ្មានអ្វីកើតឡើងទាល់តែសោះ ។ បូករួមសេចក្តីទៅ ស្តេចទាំងពីរអង្គនេះជាសម្ព័ន្ធមិត្តទៅវិញទេតើ ។ ទៅថ្ងៃមុខទៅ ស្តេចសីហនុចោទទ្រង់សិរិមតៈថា មានគោលបំណងចង់ដណ្តើមព្រះរាជបល្ល័ង្ក ។ រឿងនេះពុំពិតទាល់តែសោះ ។ ទ្រង់សិរិមតៈពុំមានឋានៈជា«ព្រះអង្គម្ចាស់»នោះទេ (កូនស្តេចសោយរាជ្យ) ដូចជាស៊ីសុវត្ថិ-មុនីរេតជាដើម... ដូច្នេះទ្រង់ពុំមានសិទ្ធិទាមទារយកព្រះរាជបល្ល័ង្កសោះឡើយ ។ ម៉្យាងវិញទៀត បើទោះជាទ្រង់ត្រូវដើរឃ្លាងផ្លូវពីស្តេចសីហនុក្តី ក៏ទ្រង់សិរិមតៈនៅតែជាព្រះរាជបំរើដ៏ស្មោះស្ម័គ្រនៃព្រះមហាក្សត្រីយានីកុសុមៈ ។ ម៉្យាងវិញទៀត ទ្រង់សិរិមតៈក៏ធ្លាប់មានឋានៈជាឪពុកធម៌របស់អ្នកម្នាងម៉ូនិកផងដែរ ដែលជាប្រពន្ធសម្លាញ់របស់ព្រះប្រមុខរដ្ឋ ។ កូនរបស់ទ្រង់ម្នាក់ គឺទ្រង់សេរីរ័ត្នក៏បានរៀបការជាមួយនឹងម្ចាស់ក្សត្រីអារុណា ដែលត្រូវជាកូនស្រីរបស់ស្តេចសីហនុ ។ ប្អូនប្រុសរបស់ទ្រង់ម្នាក់ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ-មេធាវី ក៏បានរៀបការជាមួយអ្នកស្រីណាណែត-អ៊ីស៊ី ដែលត្រូវជាបងស្រីរបស់ម៉ូនិក-សីហនុ ។ គិតសព្វៗទៅ វាហាក់ដូចជាថា ស្តេចទាំងពីរអង្គនេះ គ្មានលទ្ធភាពជំរះបញ្ជីគ្នាជាសាធារណៈ ឬក៏គងដាវគ្នានៅកណ្តាលអង្គសមាជផងសោះ ។ មហាជនខ្មែរហាក់ដូចជាមិនសូវយល់ អំពីជំរៅបុព្វហេតុនៃទំនាស់ទាស់ទែងគ្នា រវាងស្តេចទាំងពីរអង្គនេះទេ ។

⌘

(នៅមានត)